**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣

លេខ 19/2003 កបធ

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណាសម្តេចព្រះនរោត្តម សីហនុ**

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

សូមទ្រង់ព្រះមេត្តាជ្រាប ។

**<u>កម្មវត្ថុ</u>** : ការយាងទៅបើករដ្ឋសភានៃនីតិកាលទី ៣

**<u>យោង</u>** : ព្រះរាជសារ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣

ទូលព្រះបង្គំយើងខ្ញុំ ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានទទួលព្រះរាជសារ ដូចមានយោងខាងលើ បានរួមប្រជុំក្រុមប្រឹក្សាធម្មនុញ្ញនៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣ ហើយបានសម្រេចជាឯកច្ឆ័ន្ទថា តាមមាត្រា ៨២ នៃរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រត្រូវកោះប្រជុំបើកសម័យប្រជុំដំបូងរដ្ឋសភា ៦០ ថ្ងៃ យ៉ាងយូរ ក្រោយពេលបោះឆ្នោត ។ ព្រះរាជវត្តមាននៃព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ក្នុងការបើកសម័យប្រជុំដំបូងមានសារសំខាន់ណាស់ចំពោះប្រជាជាតិទាំងមូល និង ចំពោះស្ថាប័នដ៏កំពូលនេះ ។ ជាទម្លាប់កន្លងមកព្រះករុណាតែងតែទ្រង់បានផ្តល់កិត្តិយស ដោយព្រះអង្គទ្រង់បានយាងទៅជាព្រះរាជអធិបតីនៃពិធីបើកសម័យប្រជុំដំបូងរបស់រដ្ឋសភា ។

អាស្រ័យហេតុនេះ ទូលព្រះបង្គំយើងខ្ញុំ សូមព្រះរាជានុញ្ញាតថ្វាយយោបល់ថា ព្រះករុណាត្រូវយាងទៅបើករដ្ឋសភានៃនីតិកាលទី ៣ នេះ ។

សូមក្រាបបង្គំទូលថ្វាយ ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ជាទីបំផុត ។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស ។

ព្រះរាជាណាចក្រកម្ពុជា ប្រ. ក្រុមប្រឹក្សាធម្មនុញ្ញ

បិន ឈិន